ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...៤៦២.....សហវ-ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ ២០១០

# ប្រកាស
## ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង
## ដើម្បីចុះពិនិត្យ និងវាយតំលៃលើផលប៉ះពាល់ដល់សំណង់ ផ្ទះសម្បែង ដីធ្លី
## របស់ប្រជាពលរដ្ឋ ដែលប៉ះពាល់ដោយសារគម្រោងស្ថាបនាឡើងវិញកំណាត់
## ផ្លូវជាតិលេខ ៥៩ ក្នុងខេត្ត (បាត់ដំបង - ប៉ៃលិន)

*************

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រឹត្យលេខ ០៤.អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋាន មួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែមនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-លិខិតលេខ ១០០៧ សក ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១០ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន

-ចំណារឯកភាពរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១០ លើលិខិតលេខ ២៩៧៦ សហវ ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១០ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-លិខិតលេខ ៣០០៨ សក.ជក ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១០ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន

-លិខិតលេខ ៤៨៥ ដនស ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១០ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-យោងតាមតំរូវការចាំបាច់នៃការងារ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

## **<u>សំរេច</u>**

**ប្រការ១** ÷ បង្កើតគណៈកម្មការអន្តរក្រសួងមួយដើម្បីពិនិត្យ និងវាយតំលៃលើផលប៉ះពាល់ដល់សំណង់ ផ្ទះសម្បែង ដីធ្លី របស់ប្រជាពលរដ្ឋ ដែលរងនូវផលប៉ះពាល់ដោយសារគម្រោងសាងសង់ផ្លូវជាតិលេខ ៥៩ ក្នុងខេត្តបាត់ដំបង និងប៉ៃលិន ។

**ប្រការ២** ÷ គណៈកម្មការអន្តរក្រសួងនេះ មានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-ឯកឧត្តម **ញាណ ឡេង** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២-ឯកឧត្តម **ខឿ ទិសុត** | អគ្គលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៣-លោក **គី សុភាត់** | អគ្គនាយករង នៃអគ្គនាយកដ្ឋានសាធារណការនៃក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៤-លោក **ចាន់ ប៊ុណ្ណារ៉ាត់** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៥-លោកបណ្ឌិត **ឈន សុភាព** | ប្រធាននាយកដ្ឋានដោះស្រាយផលប៉ះពាល់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦-លោក **អ៊ឹម សិទ្ធីរ៉ា** | អនុប្រធាននាយកដ្ឋានដោះស្រាយផលប៉ះពាល់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧-លោក **ស៊ុខ សុគន់** | ប្រធាននាយកដ្ឋានផែនការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៨-លោក **ម៉ែន ដារ៉ាមុនី** | ប្រធានការិយាល័យគំរោងទ្វេភាគី នាយកដ្ឋានដោះស្រាយផលប៉ះពាល់ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៩-លោក **ហ៊ីច បញ្ញារិទ្ធ** | ប្រធានការិយាល័យរដ្ឋបាល និង ហិរញ្ញវត្ថុ នាយកដ្ឋានដោះស្រាយផលប៉ះពាល់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

**ប្រការ៣** ÷ គណៈកម្មការអន្តក្រសួងមានភារកិច្ចចុះពិនិត្យដល់ទីកន្លែងគម្រោង ធ្វើស្ថិតិរៀបចំចងក្រងទិន្នន័យសំណង់ ផ្ទះសម្បែង ដីធ្លី របស់ប្រជាពលរដ្ឋ ដែលរងនូវផលប៉ះពាល់ដោយសារគម្រោងស្តារឡើងវិញផ្លូវជាតិលេខ៥៩ ក្នុងខេត្តបាត់ដំបង និងប៉ៃលិន និងធ្វើការវាយតំលៃទ្រព្យសម្បត្តិដែលរងនូវផលប៉ះពាល់ទាំងនោះ សំរាប់ចងក្រងជាសៀវភៅផែនការសកម្មភាពនៃការតាំងទីលំនៅឡើងវិញ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យនិងសំរេចដែលជាមូលដ្ឋានសំរាប់ដោះស្រាយគោលនយោបាយជូនដល់ប្រជាពលរដ្ឋ ដែលរងនូវផលប៉ះពាល់ដោយសារគម្រោងខាងលើ ។

**ប្រការ៤** ÷ គណៈកម្មការនេះមានសិទ្ធិបង្កើតក្រុមការងារ សំរាប់បំពេញការងារប្រចាំថ្ងៃនៅតាមគម្រោងខាងលើ ។

**ប្រការ៥** ÷ សាមុីខ្លួន នាយកដ្ឋានដោះស្រាយផលប៉ះពាល់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារៈកិច្ចអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**<u>ចម្លងជូន ៖</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសាធារណការ និងដឹកជញ្ជូន
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-សាលាខេត្តបាត់ដំបង និងខេត្តប៉ៃលិន
-ដូចប្រការ៥ ដើម្បីអនុវត្ត
-ឯកសារ-កាលប្បវត្តិ